# ការសំភាសន៍របស់បងស្រី ជិម សុខាន់

ក ៖ អ្នកសំភាសន៍មានឈ្មោះ អ៊ុំ កន្និកា ខ ៖ អ្នកដែលត្រូវគេសំភាសន៍ ជិម សុខាន់

កៈ ជាកិច្ចដំបូងសូមគោរពជំរាបសួរបងស្រី ហើយក៏សូមថ្លែងអំណរគុណដល់បងស្រីដែលបានផ្តល់ពេលវេលានិងឱកាសដើម្បីសំរាប់អោយប្អូនអាចអង្គុយដើម្បីបានជជែកពិភាក្សាទាក់តងទៅនិងជីវប្រវត្តិរបស់បងស្រីផ្ទាល់ហើយក៏ដូចជាការសំភាសន៍មួយនេះគឺធ្វើឡើងដោយមានការផ្តួចផ្តើមឡើងដោយសាលាសកលវិទ្យាល័យ"ប៊ីវ៉ាយយូ"(BYU)ដោយសារតែសកលវិទ្យាល័យរបស់ពួកយើងមានបណងចង់ថរក្សានូវជីវប្រវត្តិរបស់បងស្រីទុកសារប់កូនចៅជំនាន់ក្រោយជាពិសេសគឺកូនៗរបស់បងដើម្បីអោយគាត់បានដឹងពីជីវប្រវត្តិរបស់បងផ្ទាល់ដើម្បីទុកជាទុនមួយសំរាប់ដឹងនាំជីវិតរបស់ពួកគេអញ្ចឹងអ្នកសបងហើយដូចជាបន្ទាប់ពីការបញ្ចប់នូវការថតសំលេងមយនេះពួកយើងសុំការអនុញ្ញាតពីបងដើម្បីដាក់សំលេងមួយនេះចូលទៅក្នុងគេហទំព័ររបស់ពួកយើងដើម្បីអោយក្មេងៗជំនាន់ក្រោយគេអាចបានដឹងលឺអញ្ចឹងណាំបងណាំដែលមានឈ្មោះថា( www.cambodia.noralhistory@by.edu )ផងដែរហើយខ្ញុំជាអ្នកសំភាសន៍មានឈ្មោះថា អ៊ុំ កន្និកា ហើយកាលបរិច្ឆេតគឺនៅថ្ងៃទី ២៤ ខែ ០២ ឆ្នាំ ២០១៨ ហើយនៅម្ដុំភូមិព្រែកទាល់ផងដែរហើយយើងនិងទៅជួបជាមួយគាត់ទាំងអស់គ្នា។ ជំរាបសួរបងស្រី.....!

ខៈ ចាំ....! ជំរាបសួរ។

កៈ តើបងស្រីមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំឈ្មោះ ជិម សុខាន់....

កៈ ជិម សុខាន់....? តើបងស្រីមានឈ្មោះហៅក្រៅទេ?

ខៈ អឺ.....ឈ្មោះក្រៅហៅឈ្មោះម៉ែអាមិន...!

កៈ ម៉ែអាមិន......?

ខៈ ចាំស....!

កៈ អញ្ចឹងពេលគេហៅនេះបងមានគ្រួសារហើយមែនទេបងបានជាគេប្តូរមកដាក់បែបនិង?

ខៈ ចាំ...!

កៈ ចុះតើបងស្រីមានអាយុប៉ុន្មានហើយ?

ខៈ ញ៉ុមអាយុសាមសិបប្រាំបី.....!

កៈ សាមសិបប្រាំបីណោះបងណោះ? ចុះតើបងនៅចាំអំពីថ្ងៃខែឆ្នាំកំណើតរបស់បងទេ?

ខៈ អ្ហឺស.....អត់ចាំទេតែ....!

កៈ អញ្ចឹងបងអាចចាំឆ្នាំបានទេ?

ខៈ ឆ្នាំញ៉ុមឆ្នាំ វក ....

កៈ ឆ្នាំ វក ណោះបងណោះ?

ខៈ ចាំ.....!

កៈ តើដូចជាអិម.....រៀបអាពាហ៍ពិពាហ៍នេះតងពីបងមានអាយុប៉ុន្មានដែរ?

ខៈ ខ្ញុំមានគ្រួសារអាយុដប់ប្រាំបួនឆ្នាំ......

កៈ អំ.....អាយុដប់ប្រាំបួនឆ្នាំណោះបង?

ខៈ ចាំស.....!

កៈ តើអាពាហ៍ពិពាហ៍នេះជាការរៀបចំពីឪពុកម្តាយមែនអ្ហេសបង?

ខៈ អត់....! អត់ញ៉ុមអត់មានម៉ែផងញ៉ុមដើរនៅជាមួយគេតាំងពីក្មេងអ្ហោះ .....!

កៈ អូ....ចាំស!

ខះ ដល់ពេលហើយ....មើសម៉ែខ្ញុំស្លាប់ចោលខ្ញុំតាំងពីអាយុប្រាំបីឆ្នាំ!

កះ ប្រាំបីឆ្នាំបងណោះ?

ខះ ចាំ...ម៉ែខ្ញុំនិងគាត់បានឪពុកដើមខ្ញុំនៅកំពង់ចាមអ្នក.....ដល់ពេលហើយគាត់ថាគាត់អត់ស្រលាញ់បព្រោះចាស់ទុំបង្ខំអញ្ចឹងទៅគាត់ថាអត់ស្រលាញ់អញ្ចឹងអ្ហាស! ពេលនិងគាត់មានទំងន់ខ្ញុំនៅនិងពោះនិងគាត់រត់ចោលឪពុកខ្ញុំនៅស្រុកនិងម៉ោយកឪពុកក្រោយខ្ញុំរាល់ថ្ងៃនេះ.....ទៅបានកើតញ៉ុមនៅភ្នំពេញនិងបានគាត់....កើតខ្ញុំហើយបានគាត់យកឪក្រោយនិងបានប្អូនប្រុសមួយដល់ពេលហើយក៏គាត់ស្លាប់ទៅក្រោយកើតអាអូនហើយដែរគេថាអាជំងឺកើតមហារីកអ្ហោះ.....

កះ ចាំ......

ខះ ស្លាប់ទៅ......ខ្ញុំទើបនិងប្រាំបីឆ្នាំទេ....អត់ដឹង! អត់ចេះយំមិចផងនិង ឃើញតែគេយំ......!
ដល់ពេលហើយ...ខ្ញុំក៏ត់ដឹងថាឪពុកខ្ញុំនៅជាមួយនិងឪពុកចុងដែរដល់តែពេលគាត់យកប្រពន្ធមួយទៀតាត់ប្រើយើងយួរទឹក...យួរទឹក! មើសកាលនិងផ្ទះនៅផ្សារចាស់...

កះ ចាំ....!

ខះ ផ្ទះនៅជិតផ្សារចាស់នៅក្បែរោងគុនហែមជាលោកគ្រូឯងស្គាល់អត់ធ្លាប់លឺសូរអត់?

កះ ចាំ.....!

ខះ និង...! ពីមុនខ្ញុំនៅនុង ដល់ពេលហើយអឹក....ទឹកនៅខាងក្រោមយួរអាកាដុងយើងប្រាំឋលីត្រនិងយួរឡើងម៉ោមកដល់ជាន់ចុះមកក្រោមឡើងដល់ជាន់ទីប្រាំខ្ញុំដងទឹកអោយគាត់ងតអ្ហាំស.....ដល់ហើយមើលកូនគាត់ឪក្រោយនិងនិយាយរួមម៉ែចុងឪចុង!

កះ ចាំ....!

ខះ អត់មានឪពុកបង្កើតទេគាត់ស្លាប់អស់ហើយជំនាន់អាពតអ្ហោះ! ដល់ពេលខ្ញុំ....គាត់រ៉ៃធ្វើបាបញ៉ុពេកខ្ញុំមកនៅជាមួយខាង....ត្រូវជាក្មួយឪពុកចុងញ៉ុមនិងអ្ហាំសស្រីអ្ហាសខ្ញុំមកនៅជាមួយគាត់រហូតដល់តែប្តីខ្ញុំឃើញហើយគា

ត់ចូលដណ្តឹងទៅបានមីងខ្ញុំគាត់អ្នករៀបចំអោយវាមិនបានការអីអធឹកអធមគ្រាន់តែសែនអីអញ្ជើងដើម្បីអោយចាស់ទុំដឹងលឺអញ្ជើងអ្នកស...!

ក៖ ចាំ....បង!

ខ៖ ហើយប្តីញុំមគាត់ធ្វើ.....និយាយរួមម៉ែឪបងប្អូនអីអត់មានទេចុះបើគាត់រត់ចោលនៅស្រុកកំពង់ចាមនិងម៉ោងនេសយើងនៅទូចនិងយើងមិចដឹងយើងនៅមួយគេទាល់តែមានប្តីហើយគាត់ពិបាកទៀតនាគពិបាកអី....គាត់អ្នកផឹកស្រាផឹកអីទៅស្រវឹងគាត់ធ្វើបាបយើងធ្វើអីចឹងញុំមចេះតែតស៊ូរហូតដេរបាវរើសអេតចាយអីក៏ធ្វើដែរអោយតែបានចិញ្ចឹមកូន....!

ក៖ ប្តីរបស់បងនេះអីបង.....?

ខ៖ ចាំ....! គាត់អ្នកញាណស្រាគាត់វ៉ៃញុំមធ្វើបាបរហូត....តែញុំមចេះតែទ្រាំទៅ!

ក៖ គាត់ឈ្មោះអីគេដែរបង?

ខ៖ ប្តីញុំមអ្ហេស?

ក៖ ចាំ.....!

ខ៖ ប្តីញុំមឈ្មោះ ព្រំ ចាន់ថា....

ក៖ អូ.....ចាំ...!

ខ៖ តែញុំមចេះតែស៊ូទ្រាំទៅ!

ក៖ គាត់មានអាយុប៉ុន្មានហើយ?

ខ៖ គាត់សែសិបជាងហើយ!

ក៖ ចា.....!

ខ៖ ហើយខ្ញុំចេះតែតស៊ូទៅព្រោះញុំមនឹកឃើញថាយើងគ្មានម៉ែគ្មានឪកំព្រាបើយើងលែងលះជាមួយប្តីទៀតមិន

ដឹងយើងទៅនៅណាទេព្រោះអីចង់អោយកូននៅរៀននៅកន្លែងអង្គការយើងនេះផងអ្នកាស!

កៈ ចាំ....ហើយក៏មិនចង់អោយកូនព្រាត់ប្រាស់ម៉ែឪដែរ...!

ខៈ ចាំយើងធ្លាប់ព្រាត់ប្រាស់ម៉ែឪហើយយើងដឹងទោះគាត់ផឹកមិចផឹកទៅញ៉ុមចេះតែទ្រាំនៅជាមួយគាត់អីណាស់ព្រោះប្ដីញ៉ុមខុសពីខ្ញុំគេលែងគាត់ចោលយូរហើយព្រោះគាត់ធ្វើបាបខ្ញុំរហូតនិងគាត់ស្រវឹងហើយតលូវគាត់លែងវ៉ៃញ៉ុមដោយសារអីបានខាងអង្គការស្តុតនិងគេយកគាត់ទៅដាក់មណ្ឌលកែប្រែអញ្ចឹងអ្នកាសដូចថាយកទៅដាក់យូរ!២ម្តងអញ្ចឹងអ្នកាសអោយគាត់ផ្តាច់ស្រាអ្នកាសចឹងបានម៉ោវិញគាត់លែងវ៉ៃធ្វើបាបខ្ញុំដូចមុនទេ....!

កៈ ចាំ......!

ខៈ ហើយខ្ញុំកូនដល់ទៅប្រាំពីរនាក់ហើយណោះនិង.....

កៈ អ៊ូ ......ចាំ!

ខៈ កូនច្រើនអ្នកាស.....!

កៈ ចុះបងអាចប្រាប់ខ្លះៗអំពីឈ្មោះគ្រួសៗទាក់ទងនិងកូនរបស់បងបានទេដូចជាកូនច្បងមានឈ្មោះអីដែរ?

ខៈ កូនខ្ញុំបងគេឈ្មោះព្រំ រតន:....

កៈ ចាំ.....!

ខៈ ប្រុសប្រាំមួយស្រីតែមួយទេ....!

កៈ ប្រុសប្រាំមួយស្រីតែមួយទេ....?

ខៈ ចាំស....!

កៈ ចុះកូនបន្ទាប់ទៀតមានឈ្មោះអីដែរ?

ខៈ ឈ្មោះ ព្រំ រតនា និងស្រីនិងទីពីនិង!

កៈ ចាំ.....!

ខៈ ក្រោយម៉ោប្រុសៗៗទាំងអស់! អាមួយទូចនោះពៅគេ....

កៈ កូនបន្ទាប់ទៀតមានឈ្មោះអីដែរបង?

បន្ទាប់ពីកូនបងឈ្មោះ រតនា នោះម៉ោ?

ខៈ មើសមិញ ព្រំ រតនៈ,ព្រំ រតនា ហើយ ព្រំ រដ្ឋារិទ្ធ ព្រំ សារ៉ាត់,ព្រំ ភារុម្យ,ព្រំ ភារក្ស និង ព្រំ សម្បត្តិ ប្រាំពីរនាក់ ចាំ....

កៈ សុទ្ធតែឈ្មោះពិរោះៗណោះបង?

ខៈ ចាំស....! ហើយខ្ញុំចេះតែតស៊ូទៅនឹកឃើញថាយើងកំព្រាអត់ម៉ែអត់ឪហើយយើងទ្រាំប៊ិននិងឆាកជីវិតយើងមិនបាន! កូនវានិងព្រាត់ប្រាស់វាតតំណែងពីខ្ញុំអញ្ចឹងអ្នកអក្សរក៏ត់បានរៀនអក្សរមួយតួក៏អត់ចេះដែរខ្ញុំអ្ហោះ! អញ្ចឹងបានខ្ញុំខំអោយកូនរៀន....

កៈ ចាំ....! អញ្ចឹងបងស្រីអត់បានរៀនអីអក្សរទេ?

ខៈ អត់សោះ....! បានរៀនអីបើម៉ែងាប់ចោលឪក្រោយគាត់មានប្រពន្ធក្រោយទៀតហើយគាត់មិនមានកូន....ដល់ពេលគាត់មានកូនគាត់ទុកអោយយើងមើលកូនគាត់!

កៈ ចា....!

ខៈ អញ្ចឹងខ្ញុំអត់បានរៀទេ...ហើយជំនាន់និងមានអង្គការម៉ោពីណាបានជួយអោយរៀនអញ្ចឹង! ?អត់ផងនិង....!

កៈ អញ្ចឹងបងស្រីអត់ចេះសរសេរអត់ចេះអានអត់ចេះអក្សរទេ?

ខៈ ចាំ.....! អត់ចេះទេ! ខ្ញុំនៅជាមួយគេរហូតដល់អាយុជិតមួយម្ភៃបានមានប្តី...អ្ហើយល្វីងជូរចត់ណាស់ខ្ញុំប្រវត្តិខ្ញុំ...ពិបាកជាងគេ!

កៈ បងធ្វើការងារអីខ្លះនៅពេលដែលបងនៅជាមួយឪពយកម្តាយចុងរបស់បង គេប្រើអោយធ្វើអីខ្លះ? ក្រោពីរែក

ទឹកអីណាស់?

ខ៖ ដងទឹក....ដងទឹកមើលប្អូន...បោសផ្ទះ ដាំបាយដាំអីស៊ីបោកខោអាវបោកអីមួយសព្វម៉ងនិងអ្នាស!

ក៖ ហត់នឿយអ្នាណោសបងណោស?

ខ៖ ចាំ.....ហត់ហើយគាត់វ៉ៃទៀត គាត់ដើរផឹកដើរស៊ីកាលនិងគាត់ញាណស្រាអ្នាស! តែតលូវគាត់លែងផឹកហើយ.....គាត់ផឹកអញ្ចឹងគាត់វ៉ៃខ្ញុំសន្លប់ណោកមើលក្បាលអីនេកលោកគ្រូឯងមើលទៅនាគខ្ញុំអត់កុហកទេណេកបែកអ្នេកគាត់វ៉ៃយើងទៅអុកនិងអាពាងជំនាន់មុនអាពាងប្រហុកអាក្តិតកាតុលកាតុលមាត់នេះអ្នោះ គាត់វ៉ៃសន្លប់ឆ្អើរភ្លើងអញ្ចឹងទៅដល់ពេលហើយអ្នកជិតខាងគេចេះតែថា....គេចេះតែលួចប្រាប់ទៅណាស់ថានិងមិនមែនឪបង្កើតទេឪចុងនិងអ្នាស តែខ្ញុំអត់ជឿចុះបើនៅជាមួយគាត់តាំងពីទូចម្លេះ...ដល់ប្រាំបីឆ្នាំបានម៉ែខ្ញុំស្លាប់និង!

ក៖ ចុះបងមានស្គាល់ឈ្មោះម៉ាក់បងទេម្តាយបង្កើតបងមានឈ្មោះអី?

ខ៖ អឺ....ម៉ែបង្កើតខ្ញុំឈ្មោះ ស្រី បាន....

ក៖ ស្រី បាន....?

ខ៖ ចាំ....!

ក៖ ចុះឪពុកបង្កើតវិញឈ្មោះអីដែរ?

ខ៖ ឪពុកបង្កើតឈ្មោះ ខា....

ក៖ ឈ្មោះ ខា...?

ខ៖ ចាំ....តែគាត់ស្លាប់ជំនាន់អាពត...ឪខ្ញុំស្លាប់ជំនាន់អាពតតែម៉ែខ្ញុំទើបនិងស្លាប់ប្រហែលខ្ញុំនៅក្មេងនេះទេ....

ក៖ ចាំ...,!

ខ៖ ហើយដល់ពេលបានប្តីម៉ោ...ប្តីធ្វើបាបទៀត...

កៈ ធ្វើបាបម៉ាក់បងណោះបងណោះ?

ខ ធ្វើបាបអ្ហាស....នៅម្ដុំនេះអ្នកណាក៏គេដឹងដែរអញ្ចឹងបានថាជីវិតនេះខ្ញុំអត់ចង់អោយកូនបែកបាក់ទេ....ដូចខ្ញុំអញ្ចឹងអ្ហ៎ាស!

កៈ ចាំ....!

ខៈ ខ្ញុំនេះក៏ចេះតែទ្រាំទៅ......

កៈ ទ្រាំ...! ឥលូវបានសម្រេចហើយលោកពូឥលូវគាត់អត់សូវដូចពីមុនអ៊ីណ៎ាបង?

ខៈ ចាំ....!គាត់អត់សូវដូចមុនកូនអីកិច្ចការងារផ្ទះអីគាត់ចេះជួយអត់ដូចពីមុនអត់ទេ...គាត់ផឹកម៉ោពីផឹកវ៉ៃយើងម៉ង! វ៉ៃយើងហើយជេរបោករបស់របរខ្ទិចខ្ទីអស់ហើយ....។

កៈ ចាំ......!អញ្ចឹងកូនរបស់បងដែរនៅរៀននៅក្នុងបន្ទុករបស់បងសព្វថ្ងៃប៉ុន្មាននាក់ដែរ?

ខៈ បន្ទុក! នៅជាមួយខ្ញុំទាំងអស់....!

កៈ អញ្ចឹងអ្ហោះបង?

ខៈ ចាំ....!

កៈ អត់មានអ្នកណាគេចេញក្រៅដូចថាមានគ្រួសារអីអត់មានទេ?

ខៈ នៅ...! មានគ្រួសារអីបើបងគេទើបនិងអាយុដប់ប្រាំបីឆ្នាំហើយស្រីនិងទបនិងដប់ប្រាំពីរឆ្នាំនិង!

កៈ តែឥលូវនិងពួកគាត់ចេញទៅធ្វើការងាររៀងៗខ្លួនអស់ហើយ?

ខៈ ចាំ...ទៅធ្វើអស់ហើយ! ទីធ្វើការជួយគ្រួសារខ្លះទៀតគាត់ចង់បានម៉ូតូអីអញ្ចឹងអ្ហាសគាត់រកលុយដើម្បីទៅទិញចឹងគាត់ធ្វើបង់រំលោះអីចឹងអ្ហាស!

កៈ ចាំ....! ចុះតើទីកន្លែងកំណើតរបស់បងស្រីវិញនៅទីណា៎ដែរ?

ខ៖ ស្រុកកំណើតខ្ញុំបើគិតទៅនៅភ្នំពេញនិងឯងគ្រូដោយសារ....តែបើស្រុកកំណើតម៉ែខ្ញុំម៉ងនៅកំពង់ចាម!

ក៖ ឪពុកក៏នៅកំពង់ចាមដែរ?

ខ៖ ឪពុកអត់ដឹងគាត់កើតនៅឯណាទេគ្រាន់តែខ្ញុំបានដឹងឈ្មោះគាត់តែពេលខ្ញុំកើតខ្ញុំបានកើតនៅភ្នំពេញនិង!

ក៖ ម៉ាក់របស់បងពេលនិងគាត់ឡើងមកភ្នំពេញហើយមកកើតបងនៅភ្នំពេញ....

ខ៖ ចាំ....!

ក៖ នៅពេទ្យណាំដែរបង? ខ៖ កាលនិងញ៉ុមស្រលាញ់ការងារខាងពេទ្យអឺក....ពេទ្យជាកនេះពេទ្យអង្គឌួងមុន អ្នាំស...មុនពេទ្យអង្គឌួងនិងពេទ្យបង្កើតកូន...

ក៖ ចាំ....!

ខ៖ នេះបើតាមខ្ញុំចាំបានអ្នាំ......កាលនៅទូចៗ។

ក៖ ចុះបងស្រីមានបងប្អូនបង្កើតប៉ុន្មាននាក់ទៅ?

ខ៖ មានតែពីរនាក់និង....

ក៖ ម្នាក់ទៀតស្រីក៏ប្រុស?

ខ៖ ប្រុស....!

ក៖ តើគាត់នៅរស់ដល់សព្វថ្ងៃទេ?

ខ៖ ចាំ...នៅ!

ក៖ គាត់ឈ្មោះអីគេដែរ?

ខ៖ អ៊ឺ....តែប្អូនញ៉ុមនិងកូនប្តីក្រោយអ្នាស!

ក៖ ចាំ....!

ខះ តែគាត់មានប្រពន្ធមានកូនហើយគាត់ឈ្មោះអារិទ្ធហៅតែឈ្មោះអារិទ្ធអារិទ្ធ!

កះ អញ្ចឹងអ្ហោះ?

ខះ ចាំ....!

កះ គាត់មានប្រពន្ធកូនហើយដូច្នេះបងស្រីមានក្មួយ?

ខះ ចាំ....!

កះ តែគាត់ជាប្អូនកូនប្ដីក្រោយរបស់ម្ដាយបងទេ...!

ខះ ចាំ....! គ្រាន់តែថាយើងកើតពោះម្ដាយតែមួយ!

កះ ចាំ....!

ខះ តែបើគិតទៅយើងមិនមែនបងប្អូនបង្កើតទេតែយើងចេះតែរាប់អានគ្នាទៅ!

កះ ចាំ...អញ្ចឹងបងរាប់អានគាត់មកលេងបងអីធម្មតាទេ?

ខះ ចាំ...! ធម្មតា ឪចុងខ្ញុំរាល់ថ្ងៃនិងគាត់ធ្វើបាបខ្ញុំក៏ដោយតែតាចូលឆ្នាំភ្ជុំបុណ្យទានអីខ្ញុំនៅតែទិញរបស់របរជូនគាត់ ខ្ញុំនឹកឃើញថាពីមុនគាត់ធ្វើបាបយើងមែនប៉ុន្តែយើងដឹងក្ដីម៉ោយើងរស់នៅជាមួយគាត់អីណាំស! ដូចថាយើងជាតិមុនយើងបានជំពាក់គាត់ជាតិនេះយើងសងអោយអស់...! ខះ ប្ដីក៏ដោយខ្ញុំអត់មានគិតថាគុំគួនអីទេលោកគ្រូគ្រាន់តែដឹងថាមនុស្សម្នាក់ៗសុទ្ធតែមានកម្មតែយើងអត់ដឹងអ្ហាំស! តែជាតិនេះយើងសងគេទៅជាតិក្រោយយើងវាអស់ហើយ! ហើយខ្ញុំជាតិនេះពិបាកណាស់ ពិបាកតាំងពីក្មេងរហូតដល់អាយុប៉ុននិងហើយនៅតែពិបាក!

កះ ចាំ.....បងនឿយច្រើន!

ខះ ចាំខ្ញុំហត់រើសអេតចាយផង ដេរបាវផង...

កះ តែសព្វថ្ងៃនិងបងមានមុខរបរអីគេដែរ?

ខៈ ខ្ញុំសព្វថ្ងៃនិង...ពីមុនដេរបាវតែឥលូវធ្វើការងារនៅអង្គការមួយគឺអង្គការមូលនិធិកម្ពុជាអង្គការស្គុតនិង...!

កៈ ចាំ....!

ខៈ ចាំ...ខ្ញុំមើលក្មេងពេលយប់អូ្ហស!

កៈ អញ្ចឹងអ្ហោះបង?

ខៈ និងអ្ហើយ....!

កៈ ក្មេងៗនិងមកគេងនៅអង្គការនិងហើយបងជាអ្នកមើលថែរក្សាណោះ?

ខៈ ចាំ.....! មើលពេលយប់។

កៈ បងបានប្រាក់ខែប្រហែលជាប៉ុន្មានដែរបង?

ខៈ មួយរយជាងនិងគ្រូ!

កៈ អ៊ូ....អញ្ចឹងបានម៉ាទប់ៗណោះបងណោះ?

ខៈ ចាំ...បានម៉ាទប់ម៉ាថ្លៃផ្ទះថ្លៃទឹកនិងថ្លៃភ្លើង...!

កៈ ចាំចុះតើបងគិតថាការងារនិងរៀងធូរជាងបងទៅធ្វើការនៅខាងក្រៅឬក៏ល្អឬក៏អត់ល្អជាងបងទៅធ្វើការនៅខាងក្រៅ?

ខៈ ល្អជាង...ការងារខាងក្រៅ!

កៈ ល្អជាងណោះបង?!

ខៈ ចាំព្រោះកាងារនេះគេមានបាយមួយពេលអោយយើងទៀតណាស់ហើយឈឺស្កាត់អីគេមើល....!

កៈ ចាំ....គេមើលថែយើងបានដិតដល់!

ខៈ ចាំ....!

កៈ បង! អញ្ចឹងទាក់ទងទៅនិងជីវិតប្តីប្រពន្ធរបស់បងអ្នាស? បងមករស់នៅភ្នំពេញនិងដែរបងកើតនៅភ្នំពេញនិងជួបប្តីបងនៅភ្នំពេញហើយការរស់នៅជាមួយនិងមិនមែនដំបូងមកនៅទីនេះទេឬក៏គ្រាន់តែការហើយមកនេះមកនៅខាងព្រែកទាល់នេះម៉ង?

ខៈ អត់តេស....មុនដំបូងការហើយខ្ញុំនៅអីស្ទឹងអីសង្កាត់ផ្សារចាស់ដែលខ្ញុំប្រាប់លោកគ្រូឯងនិងថាខ្ញុំឃ្មួរទឹកឃ្មួរអីនិងអ្នាស...!

កៈ ពេលនិងបងមានប្តីហើយ?

ខៈ ចាំ...ខ្ញុំនៅនុងខ្ញុំអត់ទាន់ស្គាល់កន្លែងនេះទេ...ដោយសារខាងប្តីខ្ញុំឪចុងគាត់និងគាត់មកនៅនេះមុនខ្ញុំអ្នំស! កាលនិងកន្លែងនិងសុទ្ធតែភក់ល្បាប់គេចាក់សំរាមចាក់អីនៅនិងតែខ្ញុំទើបនិងមានកូនប្រាំនាក់ទើបមកនៅនិងអ្នាស! ដល់ពេលហើយបានខ្ញុំមកនៅនិងបានប៉ុន្មានតេសខ្ញុំបានអាទូចៗក្រោយនិងពីរនាក់ទៀត...!

កៈ ចាំ......!

ខៈ ហើយណាមួយលុយឆ្លងទន្លេឆ្លងអីក៏មិនសូវមានដេសដោយសារអង្គការអង្គអីនេះគាត់ជួយអ្នាស! ជួយថ្លៃកើតថ្លៃអីអញ្ចឹងទៅហើយខ្ញុំមានអាបំណ្ណក្រីក្រគេនិងគេជួយដែរដោយសារយើងកូនច្រើនអញ្ចឹងអ្នាសគេជួយ!

កៈ ចាំ....! គេជយបង?

ខៈ ចាំ....!

កៈ តលូវសព្វថ្ងៃនេះថ្លៃធ្វើម្ហូបមួយថ្ងៃៗប្រហែលជាអស់ប៉ុន្មានដែរបង?

ខៈ ម្ហូបតលូវថ្លៃណាស់គ្រូអើយម្ហូបយើងស៊ីរិះចាំហើយមួយថ្ងៃមួយម៉ឺនប្រាំដែរចុះកូនយើងច្រើននោះ!

កៈ ចុះនៅថ្លៃហ្គាសថ្លៃអីទៀត...?

ខៈ ចាំ....! ចាំហ្គាសផងហើយលុយកូនទៅរៀនទៅអីផងមួយថ្ងៃជិតពីរម៉ឺនជាងអ្នោះ!

កៈ ចាំ....!

ខ៖ ហើយកូនធ្វើការផងខ្ញុំធ្វើការហាងកូនពីរនាក់ធ្វើការផងហើយខ្ញុំផងទប់អត់ចងឈ្នះទេណាស...ដោយសារអីយើងចំណាយច្រើនគ្រូឯងឃើញស្រាប់ហើយកូនទៅរៀនសាលារដ្ឋអោយគ្នាតែមួយពាន់ៗទេបួននាក់ជិតប្រាំពាន់ហើយ...ហើយនៅអាធំនោះគាត់ទៅធ្វើការគាត់អ្នកយកប្រាំពាន់ទៀតបាយល្ងាចបានម៉ោផ្ទះ!

ក៖ ចាំ....ចុះបងកើតទាន់ជំនាន់អាពតទេបង? កាលជំនាន់អាពតបងអាយុប្រហែលជាប៉ុន្មានដែរ?

ខ៖ ខ្ញុំ....ចាំកាលជំនាន់អាពតខ្ញុំលឺឪចុងខ្ញុំនិយាយ...អើសមិនមែនទេគាត់និយាយកាលបែកអាពតថាបែកអាពតខ្ញុំទើបនិងចេះដើរតេសតាសនិង!

ក៖ អ៎....បងអត់ទាន់ទេ!

ខ៖ អត់ទាន់....!

ក៖ ចាំ....អញ្ចឹងអត់សូវបានជួបទុក្ខលំបាកនៅក្នុងជំនាន់អាពតនោះទេ!

ខ៖ ចាំ.....!

ក៖ ចុះបងមានចាំឈ្មោះអឺយាយតាខាងម្ដាយទេ?

ខ៖ អត់ចាំផង....ព្រោះ...

ក៖ ព្រោះម្ដាយគាត់ឆាប់ស្លាប់ពេក...!

ខ៖ ចាំ....គាត់ស្លាប់ហើយគាត់ឆាប់ស្លាប់យើងប្រាំពីរប្រាំបីឆ្នាំក៏យើងចាំដែរតែគាត់ពោះធំខ្ញុំគាត់រត់ម៉ោភ្នំពេញនិងអញ្ចឹងគាត់កើតខ្ញុំនៅភ្នំពេញនិងមានទៅកើតនៅស្រុកឯណាអញ្ចឹងខ្ញុំ.....អត់ស្គាល់ម៉ង!

ក៖ ចាំ....អញ្ចឹងបងស្រីអត់បានស្គាល់ដាច់ខ្សែរយៈបណ្ដោយ!

ខ៖ ចាំ....ដាច់អស់....!

ក៖ អញ្ចឹងខាងឪពុកក៏បងអត់ដឹងដែរ?

ខ៖ ឪពុកក៏អត់ដឹងដែស!

ក៖ ចាំ...ចុះបងគិតថាម្តាយរបស់បងនិងឪពុករបស់បងស្រីគាត់ជាមនុស្សដែរមានអត្តចរិតបែបណាដែរសរាប់បងអ្នាំស? ដែរជាការចងចាំរបស់បង!

ខ៖ ម្តាយខ្ញុំបើខ្ញុំចាំបានគាត់....និយាយរួមគាត់ចូលចិត្តសប្បាយ....! សប្បាយច្រើនអ្នាំស....

ក៖ ចាំ....!

ខ៖ បើឪពុកខ្ញុំវិញគាត់ចូលចិត្តសប្បាយហើយគាត់ចូលចិត្តថាស្រលាញ់ប្រពន្ធថាចង់ឱបក្រសោបប្រពន្ធតែប្រពន្ធអត់ស្រលាញ់អីអញ្ចឹងអ្នាំស.....ទៅរត់ចោលគាត់...ឪពុកខ្ញុំគាត់តាមរកដែរតែរកអត់ឃើញអញ្ចឹងអ្នាំស.....

ក៖ ចាំ....!

ខ៖ ដល់ពេលហើយគាត់ស្លាប់តាំងពីពេលជំនាន់អាពតនិងទៅ! ហើយខ្ញុំក៏អត់ដឹងដែរនិយាយរួមអាប្រវត្តិអញ្ចឹងៗខ្ញុំក៏អត់ដឹងដែរតែអ្នកជិតខាងខ្ញុំ...ដូចថាអ្នកជិតខាងគាត់ចាស់ៗគាត់ដឹងលឺរឿងយើងពីទូចគាត់និយាយប្រាប់អញ្ចឹងអីណាស....!

ក៖ ចុះបងមានបងប្អូននៅក្រៅប្រទេសទេ?

ខ៖ អត់ផង.....!

ក៖ អត់ទេណោះបងណោះ?

ខ៖ អត់! មានតែពីរនាក់បងប្អូន....សុទ្ធតែអត់ដូចគ្នាអញ្ចឹងបានថាបានខំអោយកូនរៀនសុខចិត្តពិបាកយ៉ាងមិចពិបាកទៅអោយតែកូនបានរៀនចេះកុំអោយល្ងង់ខ្លៅដូចជារូបខ្ញុំ! ខ្ញុំអក្សរមិនចេះផងនិង....

ក៖ ចាំ....! អញ្ចឹងបងលើកទឹកចិត្តអោយកូនៗបងរៀនណោះបងណោះ?

ខ៖ ចាំ....!

ក៖ អញ្ចឹងអោយតែថាអោយតែមានឱកាសអីក៏បងរុញអោយកូនបងរៀន....

ខៈ ចាំ....អោយរៀនអត់អោយឈប់ទេ!

កៈ ចាំ....!

ខៈ ព្រោះអីខ្ញុំខ្លាចពិបាកតៗគ្នា....

កៈ បងតែងតែតាមដានការសិក្សារបស់គាត់រហូតអញ្ចឹងទៅ?

ខៈ ចាំ....!

កៈ ចុះរាល់ថ្ងៃនេះបងដូចថាសំរាប់បងទេណាំសតើបងគិតថាតាំងពីបងនៅក្មេងរហូតដល់សព្វថ្ងៃតើជីវិតរបស់បងមានការផ្លាស់ប្តូរអីទេ? ដូចថាធូរស្រោលជាងមុនឬក៏បែបណាអញ្ចឹងអ្នាំស?

ខៈ បើនិយាយរឿងពីមុនម៉ោកូនខ្ញុំនៅទូចៗវារៀងពិបាកនឿយជាងឥលូវបន្តិចអ្ហេស....

កៈ ចាំ.....!

ខៈ តែដល់ឥលូវនេះវាគ្រាន់កូនខ្ញុំគាត់ធំៗហើយគាត់ធ្វើការអីគាត់ចេះជួយយើងខ្លះទៅវាមិនមែនថាវាធូរម៉ងទេតែវាកាត់បន្ថយថាមួយរយអញ្ចឹងកាត់បានប៉ែតសិបភាររយអញ្ចឹងអ្នាំស!

កៈ ចាំ....!

ខៈ ចាំ....វាធូរគ្រាន់មួយកម្រិតបន្តិចគ្រាន់តែថាពីមុនប្តីខ្ញុំគាត់រកបានតែឥលូវគាត់ឈឺគាត់រកអីអត់សូវបានដូចពីមុនទេ.....

កៈ ខ្ញុំលឺគាត់ប្រាប់ថាឈឺចង្កេះណោះបង?

ខៈ ចាំ....គាត់ឈឺចង្កេះគ្រាន់ហើយឥលូវលើកមុនអង្គុយញ៉ូចនៅមួយកន្លែងនិងដើររួចកាលមុនដើរអត់រួចហាងដើរទៅដួលដាច់ដៃដាច់ជើងអស់ហើយអញ្ចឹងមានតែខ្ញុំនិងអ្នកជាជំហរកលុយ.....

កៈ ចាំ...បងស្រីជាជំហរ!

ខ៖ កាលពីមុនឡើយយើងមាមកូនទូចៗគាត់រកអីណាស់ដល់ឥលូវគាត់រកអត់បានយើងរកម្តងទៅ....!

ក៖ បងជាមនុស្សស្រីមាំទាំណាស់ណ៎....ដូចថាជាមនុស្សស្រីម្នាក់ដែរអត់ផ្អែកផ្តេកផ្តួលទៅលើប្តីអ្នាំសកាលណាតែប្តីដួលក្រិបយើងមានជំហររបស់យើង....

ខ៖ ចាំ....យើងមានជំហរ!

ក៖ យើងត្រៀមខ្លួនហើយស្រាច់នៅក្នុងការរក្សាជំហរអ្នាំស....

ខ៖ ខ្ញុំគិតថាអញ្ចេក....អឺមនុស្សស្រីក៏ដោយប្រុសក៏ដោយមិនអាចថាសង្ឃឹមប្តីមួយរយភាគរយទេថៃដន្យគាត់រកអត់បានគាត់ឈឺគាត់អីទៅយើងត្រូវស្វាតស្វែងមានការងារធ្វើ....អញ្ចឹងខ្ញុំ...ខ្ញុំគិតអញ្ចឹងខ្ញុំថាអ្នកខ្លះគេអត់គិតអញ្ចឹងទេគេគិតអ្វីសមានប្តីអាងប្តី....

ក៖ ចាំ....

ខ៖ ពេលប្តីនៅមានកលាំងចេះតែអាងបានអ្ហែចឹងដូចរូបខ្ញុំប្តីអញ្ចឹងបើយើមិនប្រឹងខ្លួនឯងបានអីកូន....ហើយកូនខ្ញុំដល់ទៅប្រាំមួយប្រាំពីរនាក់ឯណោះធំៗពេញវ៉យតាពីរនីប្រាំនាក់ទៀតកំពុងពេញរៀននិងអញ្ចឹងយើងត្រូវធ្វើហើយទទួលខុសត្រូវច្រើនហើយយូរទៀតអ្នាំណាស់!

ក៖ ចាំ....ចុះបងគិតថាប្តីរបស់បងគាត់មានអត្តចរិតបែបណាសម្រាប់បងអ្នាំស? ឥលូវនិងអ្នាំស?

ខ៖ ឥលូវនិងគាត់ល្អជាងមុន....ពីមុនម៉ោអានិងគាត់អាក្រក់អ្នាំសអានិងយើងគិតថាកាត់ចេញទៅណាស់....!

ក៖ បំភ្លេចចោល....!

ខ៖ ចាំ....ហើយបើឥលូវគាត់ធ្វើល្អវិញហើយយើងថាល្អទៅ....ព្រោះអឺមនុស្សមិនមែនចេះតែអាក្រក់ទាំងអស់ទេ.....

ក៖ ចាំ....មានចំណុចល្អនិងចំណុចអាក្រក់អញ្ចឹងអឺណាស់បង!

ខ៖ ចាំហើយមានមនុស្សល្អនិងមនុស្សអាក្រក់ !

កៈ សំរាប់បងផ្ទាល់តើការឆ្លកាត់នូវឧបសគ្គរបស់បងក្នុងជីវិតនេះតើមានអ្វីទៀតដែរបងមានបំណងចង់ចែកចាយបន្ថែមទេដែលថាមួយនិងបងឆ្លងកាត់ទាំងវេទនាអីណាស់មិនថាបងសំរាលកូនឬក៏ពេលបងកើតកូនហើយអត់មានលុយឬក៏ទុក្ខវេទនាផ្នែកអាហារដែលបងអត់មានអាហារបរិភោគគ្រប់គ្រាន់ឬក៏កាងារធ្វន់អីមួយដែរបងចងចែកចាយអ្នាស?

ខៈ ខ្ញុំចង់ចែកចាយថាអោយក្មេងស្រករក្រោយអោយខំរៀនកុំអោយពិបាកវេទនាដូចជារូបខ្ញុំចឹងអោយខំរៀនតែមួយមុខកុំអោយប្រើអាគ្រឿងញាណគ្រឿងអីដើរផ្លូវខុសនិងបើមានម៉ែមានឪអោយចេះស្រលាញម៉ែឪចេះស្តាប់ម៉ែឪអញ្ចឹងអ្នាស! បើដូចរូបខ្ញុំអត់មានម៉ែមានឪអញ្ចឹង!

កៈ បងពិបាក!

ខៈ ពិបាកអត់មានម៉ែប្រាប់អត់មានម៉ែឪប្រៀនប្រដៅចឹង.....

កៈ ចា៎....!

ខៈ ប៉ុន្តែខ្ញុំអត់មានម៉ែមានឪមកប្រដៅមែនក៏ខ្ញុំមិនដែរដើរទៅផ្លូវខុសអ្នាស! ខ្ញុំមានកូនមានប្តីខ្ញុំស្រលាញ់តែកូននិងប្តីខ្ញុំមួយខ្ញុំអត់មានចិត្តថាចង់ហាក់លោតអីព្រោះអីប្រវត្តិយើងវាកំព្រាហើយនិងលោកគ្រូ....

កៈ ចា៎....!

ខៈ អញ្ចឹងបានជាខ្ញុំផ្តែផ្តាំថាអោយក្មេងស្រករក្រោយអោយជំនាន់តលូវនាគធ្វមិចអោយគ្រប់គ្រងខ្លួនឯងចេះស្រលាញ់ម៉ែឪចេះស្រលាញ់បងប្អូនទាំងអស់ជិតខាងអីនិងមិនមែនថាតែម៉ែឪបងប្អូនយើងអ្នកជិតខាងក៏ដូចជាបងប្អូនយើងដែរពេលឈឺស្កាត់យប់ព្រលប់អីបងប្អូនណាម៉ោទាន់...នេះអ្នកជិតខាងនិងហើយឈូរឈរជួយយើងអ្ហោះ!

កៈ ចា៎....!

ខៈ អញ្ចឹងយើងមិនអាចអី...បង្កជំលោះអីជាមួយពួកគាត់អ្នកជិតខាងបានទេ....

កៈ បងស្រលាញ់អ្នកជិតខាង!

ខៈ ដូចរូបខ្ញុំផ្ទាល់នៅនេះអញ្ចឹងខ្ញុំមិនដែរទៅចេះឈ្លោះមួយអ្នកជិតខាងណាទេស...! បើថាអ្នកណាគាត់ពូកែជេរ

កុំទៅជិតគាត់ទៅកុំរវីរវល់ចប់ហើយអានិងវាអត់មានអីឈ្លោះទេ....

កៈ ចាំ....បងជាមនុស្សស្រីម្នាក់ដែរអត់ចូលចិត្តទំនាស់អ្ហាស់បងចង់តែបានសុខ....

ខៈ ណាមួយខ្ញុំទៅធ្វើការងារនៅអង្គការស្គុតនិងគេឧស្សាហ៍ហៅយើងទៅរៀនអំពីអាពាក្យយើងប្រើកោងកាចអត្តចរិតយើងនិងអ្ហាស់....គេឧស្សាហ៍ហៅទៅបង្រៀនដល់អញ្ចឹងខ្ញុំដឹងច្រើនអញ្ចឹងអីណាស់!

កៈ ចាំ....!

ខៈ ព្រោះអីកន្លែងខ្ញុំធ្វើការគេឧស្សាហ៍ហៅយើងទៅរៀនគេបង្រៀនតាំងពីការប្រើប្រាស់អត្តចរិតយើង....ស្អីៗទាំងអស់!គេមិនមែនចេះតែយកយើងទេ។

កៈ ចាំ....! ខ្ញុំគិតថាបងស្រីខ្វះភាពកក់ក្ដៅច្រើនអីណោះបង?

ខៈ ចាំស.....!

កៈ ដោយសារបងធំឡើងម៉ោបងអត់មានម៉ែឪបង្កើតអញ្ចឹងអ្ហាស់...!

ខៈ អត់មានទេ....!

កៈ ចុះឪពុកចុងបងគាត់មានធ្វើបាបបងទេ?

ខៈ អឺ...គាត់! បើនិយាយពីរឿងធ្វើបាបនោះគាត់ធ្វើបាបឆ្អែតហើយប៉ុនគ្រាន់ថាខ្ញុំអត់គុំ....

កៈ អត់គុំទេ....

ខៈ ចាំ....ហើយខែបុណ្យខែទានអញ្ចឹងខ្ញុំជូនលុយគាត់ហើយតវ៉ែតវ៉ាន់អីចឹងរាល់ឆ្នាំអត់ដែរខានទេ...ចាំទោះបីខ្ញុំអត់...ខ្ញុំអត់មែនទែនខ្ញុំសុខចិត្តជិះកង់ទៅទៀតទៅដល់ផ្ទះគាត់យកលុយយកអីអោយគាត់....អ្នកខ្លះគេថាដែរគេថាអ្ហីស...ឪចុងធ្វើបាបចង់ងាប់តែខ្ញុំគិតថាគិតធម៌ព្រះមកវិញថាជាតិមុនបែបយើងមានកម្មជាមួយគាត់មនុស្សម្នាក់ៗសុទ្ធតែមានកម្មហើយអញ្ចឹងខ្ញុំអត់គិតទេខ្ញុំនឹកឃើញថាពេលដែរយើងនៅក្នុងផ្ទៃពោះម្ដាយគាត់យកម្ដាយយើងក៏គាត់ចិញ្ចឹមម្ដាយយើងដែរលោកគ្រូអ្ហាស់គ្រាន់តែថាគាត់មិនស្រលាញ់យើងដូចកូនបង្កើតរបស់គាត់ មែន

គាត់តែងតែរ៉ៃធ្វើបាបអញ្ចឹងអីណាស់....នេះខ្ញុំគិតអញ្ចឹង....!

ក៖ ចា៎....បងស្រីមនុស្សល្អមែនទែនបងអត់ចេះគុំគួនគេយូរអ្ហេណោះបង?

ខ៖ ចា៎ខ្ញុំអត់ចេះទេ...ខ្ញុំចិត្តល្អណាស់ខ្ញុំមាន...

ក៖ ហើយចេះស្រលាញ់អ្នកជិតខាង....!

ខ៖ មែនថាមានច្រើនអីទេ...ប៉ុនគ្រាន់តែថា....

ក៖ បងមានទឹកចិត្តនិងអ្ហាស់បង...

ខ៖ ខ្ញុំមានបន្តិចបន្តួចដូចជាស្ករសទឹកត្រីអីអញ្ចឹងគាត់ខ្វះគាត់មករកអោយគេអ្ហែ....

ក៖ ចា៎....!

ខ៖ ចិត្តអត់ដាច់ទេ...

ក៖ បងឯងមានទឹកចិត្ត...! ចា៎ចុះដូចជាមុខម្ហូបវិញតើបងចូលចិត្តមុខម្ហូបបែបសម្លរឬក៏បែបឆាឬក៏បែបក្រៀមក្រោះ? ដែរថាបងចូលចិត្តអីណាស់?

ខ៖ ខ្ញុំចូលចិត្តសម្លរលោកគ្រូតែដល់ពេលកូនខ្ញុំគាត់ចូលចិត្តតែក្រៀមក្រោះ....

ក៖ កាត់ទៅប៉ាហើយមើលទៅ...(?

ខ៖ (សើច) អត់តេសប៉ាចូលចិត្តសម្លរដែរ!

ក៖ អញ្ចឹងអ្ហោះ?

ខ៖ ចា៎! តែកូនខ្ញុំគាត់បើសម្លរដឹងតែថាគាត់អត់ហូបទេ....តែបើក្រៀមក្រោះគាត់ចូលចិត្ត...! ដូចប្រឡាក់សាច់ជ្រូកប្រឡាក់ត្រីប្រឡាក់អីនិងអ្ហាស់...!

ក៖ ចា៎...!

ខ៖ ហើយខ្ញុំចេះតែថាកូនឯងកុំញ៉ាំក្រៀមក្រោះពេកវាអត់ល្អវាគ្មានកំលាំងទេញ៉ាំសម្លរញ៉ាំអីទៅវាមានកំលាំងអ្នាស...

ក៖ ចាំ....!

ខ៖ អឺគាត់ថាសម្លរអីបើគាត់អត់...បើគាត់ញ៉ាំគាត់ចូលចិត្តញ៉ាំសម្លរស្ងោរជ្រក់មាន់ហើយបើមិនអញ្ចឹងសម្លរម្ជូរគ្រឿងឆ្អឹងជំនីជ្រូក...អញ្ចឹងបានគាត់ហូបបើសម្លរម្ជូរត្រកួនត្រីតូចៗអីអត់ទៀតអត់ៗញ៉ាំទៀត.....!

ក៖ ចាំ...! ហើយចុះចម្រៀងវិញបងស្រីតើបងស្រីចូលចិត្តស្ដាប់បទចម្រៀងទេ?

ខ៖ ចម្រៀងវិញខ្ញុំចូលចិត្តស្ដាប់បទពីដើម....

ក៖ នរណាគេអ្នកច្រៀងដែរបង?

ខ៖ អឺ...ដូចថាណយ...អើសកែវសារ៉ាត់....

ក៖ រស់ សិរីសុទ្ធា អីណាណោះបងណេះ?

ខ៖ និងហើយ....

ក៖ អត់សូវចូលចិត្តបទសម៉ៃយអ្វេ...ណោះបងណោះ?

ខ៖ អត់តេស....!

ក៖ ចាំ...ចុះបងចូលចិត្តនិងចេះរាំទេ?

ខ៖ ញ៉ុម...? ខ្ញុំអត់ចេះសោះ!

ក៖ រាំប្រពៃណីអីអឺណាស់បង?

ខ៖ ប្រពៃណីចេះបើរាំអាញ៉ាក់អាញ៉ំអត់ចេះតេស...រាំវង្សរាំអី!

ក៖ រាំប្រពៃណីបើមានការចាក់អីបងអាចរាំបានមួយពួកគេ?

ខៈ  ចា៎......បើមានគេការកម្មវិធីអីភ្ជាប់ពាក្យខួបកំណើតកូនគេអីអាហៅញ៉ុមរហូតនិង....

កៈ ចា៎ចុះបងមានអីបន្ថែមដូចថាផ្ដែផ្ដាំទៅកូនចៅបន្ថែមទៀតទាក់ទងទៅនិងជីវិតរបស់ពួកគេដែររថាគួរជ្រើសផ្លូវដើរបែបណាបើសិនជាគាត់បានលឺនៅសំលេងមួយនិង...

ខៈ ញ៉ុមផ្ដែផ្ដាំថាកូនឯងកុំអោយដើរផ្លូវខុសហើយអោយខំរៀនព្រោះម៉ែឪក្រណាស់គ្មានអីចែកទេមានតែចំណេះដឹងចំណេះវិជ្ជានេះហើយចែកកូននិងហើយបើថាមានអង្គការជួយហើយខំរៀនទៅកុំអោយដើផ្លូវខុសខ្ញុំបើកូនដើរផ្លូវខុសខ្ញុំឆ្កួតម៉ង..,

កៈ បងស្រលាញ់កូនណាស់....! មិនចង់អោយកូនពិបាកទេ...!

ខៈ ចា៎.....មិនចង់អោយកូនដើរផ្លូវខុសមិនចង់អោយកូនពិបាកដូចខ្ញុំខ្ញុំពិបាកហើយនាគដូចខ្វាក់អញ្ចឹងរាល់ថ្ងៃនាគភ្នែកភ្លឺមែនប៉ុនគ្រាន់តែថាអក្សរយើងមើលអត់ដឹង....!

កៈ ចា៎....!

ខៈ អានិងដូចជាខ្វាក់ញ្ចឹង...!

កៈ ចា៎...! បង!

ខៈ អញ្ចឹងបានខ្ញុំផ្ដែផ្ដាំកូនអោយហើយធ្វើមិចមិនបាញ់អោយមាសលុយតាំងដុំៗអោយម្ដាយទេអោយតែកូនធ្វើអោយម៉ែពិបាកចិត្តអោយដើរតែផ្លូវល្អទៅខ្ញុំសប្បាយចិត្តហើយ!

កៈ ធ្វើអោយផ្លូវចិត្តរបស់បងសប្បាយចិត្តអណាស់..

ខៈ ចា៎...ខ្ញុំសប្បាយចិត្ត...!

កៈ បងចង់បានតែប៉ុននិងឯង?

ខៈ ចា៎...ខ្ញុំចង់បានតែប៉ុននិង!

កៈ ចា៎...ដូចជាពួកយើងអរគុណច្រើនដែរបងបានលះបង់និងចំណាយពេលវេលាដើម្បីពួកយើងអាចជជែក

លេងជាមួយបងទាក់ទងទៅនិងជីវប្រវត្តិរបស់បង...

ខ៖ ចាំ.....!

ក៖ ហើយឃើញថាមានការជូរចត់ច្រើនមែនទែនតែបងគឺជាមនុស្សស្រីម្នាក់ដែររឹងមាំហើយជាមនុស្សស្រីម្នាក់ដែរតស៊ូព្យាយាមពុះពារនូវរាល់ឧបសគ្គផ្សេងៗ...

ខ៖ ចាំ...!

ក៖ ហើយក៏ជូនពរបងអោយគ្រួសារបងប្រកបដោយភាពរីកចំរើនអីណាំបង!

ខ៖ ចាំ...ចាំ!

ក៖ ហើយកូនៗរបស់បងសូមអោយគាត់អាចបានរៀនចប់ហើយមានការងារធ្វើល្អមួយហើយពួកគេអាចតបស្នងបងវិញដោយក្តីស្រលាញ់ហើយនិងធ្វើអោយទឹកចិត្តរបស់បងមានអារម្មណ៍ថាសប្បាយជាងមុនទៀតអត់សូវពិបាកដូចជាពីមុនចាំអញ្ចឹងអ្នកចាស់ហើយសូមអោយបងពោរពេញទៅដោយសុខភាពល្អដើម្បីបន្តមានអាយុវែងរស់នៅជាមួយកូនចៅតៗហើយនៅមើលការរីកចំរើនរបស់ពួកគាត់ពីមួយជំនាន់ទៅមួយជំនាន់ទៀតអញ្ចឹងអីណាស់បងហើយពួកយើងមានតែប៉ុននិងតែសុំការអនុញ្ញាតពីបងស្រីដើម្បីអាចអោយពួកយើងដាក់សម្លេងមួយនេះចូលទៅក្នុងគេហទំព័រផ្ទាល់របស់ពួកយើងដើម្បីអោយកូនៗរបស់បងនិងក្មេងៗជំនាន់ក្រោយគេបានដឹងផងដែរ...

ខ៖ ចាំ..អោយគាត់ស្តាប់!

ក៖ ចាំៗហើយពួកយើងមានតែប៉ុននិងសូមគោរពជំរាបសួរបងស្រី!

ខ៖ ចាំ....អរគុណច្រើន!